# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ផ្លូវជាតិលេខ#២ ភូមិក្រសាំង ឃុំជើងកើបស្រុកកណ្តាស ខេត្តកណ្តាល

---

### កិច្ចព្រមព្រៀង

### រវាងក្រុមហ៊ុន ហ័ង ឌាន មេធៀរៀល ឯ.ក

### និង តំណាងប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋានប្រចាំក្រុមហ៊ុន ហ័ង ឌាន មេធៀរៀល ឯ.ក

### ស្តីពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ០២៖៣០នាទី នៅក្នុងរោងចក្រ ហ័ង ឌាន មេធៀរៀល ឯ.ក មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិក សហជីពមូលដ្ឋានប្រចាំរោងចក្រ ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិកទាំងអស់ពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រ ដោយសារតែក្រុមហ៊ុនយើងខ្វះការបញ្ជាទិញពីអ្នកកម្មង់ទិញដែលមិនអាចអោយចង្វាក់ផលិតកម្មរោងចក្រទាំងមូលដំណើរការបាន ហេតុដូចនេះក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងារ របស់កម្មករ និយោជិកចំនួន ៤៥នាក់ រយះពេលចំនួន ០១ខែ គឺចាប់ពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០ នៅក្នុងកំឡុងពេលនៃការព្យួរការងារនេះ កម្មករ និយោជិកបានឯកភាពទទួលនូវការផ្តល់ជូនរបស់ក្រុមហ៊ុននូវ ប្រាក់ឆ្នួលចំនួន ៣០ដុល្លា សម្រាប់កម្មករ និយោជិកម្នាក់ៗក្នុងមួយខែ។

អង្គប្រជុំបានចប់វេលាម៉ោង ០២ និង ៣០នាទី នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងខាងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួលខុសត្រូវ និង កិច្ចសហការគ្នាយ៉ាងរលូន។

ថ្ងៃព្រហស្បតិ៍ទី០៤ ១៤កើតខែជេស្ឋឆ្នាំ ជូត ព.ស២៥៥០

ធ្វើនៅ.កណ្តាល ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០

ស្នាមមេដៃតំណាងប្រតិភូពេញសិទ្ធ និងសហជីព

ទន់ ភារ៉ូ      ស៊ាន សួនី

នាយកក្រុមហ៊ុន

张志铭